ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៣១៧ ឧវិបន.ខល.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការចាត់តាំងក្រុមអ្នកនាំពាក្យ
# របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ត្រូវបានចាត់តាំងក្រុមអ្នកនាំពាក្យរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានសមាសភាព៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម **ហេង សុខគង់**<br>លេខទូរស័ព្ទ៖ 017 343 536 | រដ្ឋលេខាធិការ | ប្រធាន | ទទួលកិច្ចការពាក់ព័ន្ធវិស័យឧស្សាហកម្ម, សហគ្រាសធុន តូច និងមធ្យម, សិប្បកម្ម |
| ២. | ឯកឧត្តម **ជាវ អានសាន**<br>លេខទូរស័ព្ទ៖ 088 868 7888 | រដ្ឋលេខាធិការ | អនុប្រធាន | ទទួលកិច្ចការពាក់ព័ន្ធគោលនយោបាយ និងកិច្ចការទូទៅរបស់ក្រសួង |
| ៣. | ឯកឧត្តម **ហ៊ុល សៀងហេង**<br>លេខទូរស័ព្ទ៖ 092 750 724 | អនុរដ្ឋលេខាធិការ | សមាជិក | ទទួលកិច្ចការពាក់ព័ន្ធវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ៤. | ឯកឧត្តម **ស៊ាង សុលក្ខណ៍**<br>លេខទូរស័ព្ទ៖ 012 988 388 | ទីប្រឹក្សា | សមាជិក | ទទួលកិច្ចការពាក់ព័ន្ធវិស័យទឹកស្អាត មាត្រាសាស្ត្រ ស្តង់ដារ និងអាណត្តិដទៃផ្សេងទៀតរបស់ក្រសួង។ |

**ប្រការ២.-**

អ្នកនាំពាក្យរបស់ក្រសួងមានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គ្រប់គ្រងលើការងារផ្សព្វផ្សាយព័ត៌មានផ្លូវការរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ជំរុញលើកកម្ពស់របៀបវារៈអាទិភាព ផ្សព្វផ្សាយគំនិតផ្តួចផ្តើម និងសមិទ្ធផលសំខាន់ៗរបស់ក្រសួង
- ធ្វើជាជនបង្គោលរបស់ក្រសួងក្នុងការឆ្លើយឆ្លងជាផ្លូវការជាមួយសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ
- ពិនិត្យតាមដានព័ត៌មានពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីធានាថា ក្រសួងឧ.វ.ប.ន. និងស្ថាប័នក្រោមឱវាទក្រសួងត្រូវបានរាយការណ៍ប្រកបដោយសុក្រិតភាព ជាមួយព័ត៌មានពិត និងត្រឹមត្រូវ
- រៀបចំសន្និសីទសារព័ត៌មាននានា សម្រាប់ថ្នាក់ដឹកនាំក្រសួងឧ.វ.ប.ន.
- ធ្វើសេចក្តីប្រកាសព័ត៌មានទៅតាមកាលៈទេសៈតម្រូវ ដើម្បីផ្សព្វផ្សាយ គូសបញ្ជាក់ ឬបំភ្លឺអំពីកិច្ចការ ឬគោលជំហរ របស់ក្រសួង តាមការណែនាំ តម្រង់ទិសរបស់រដ្ឋមន្ត្រី
- បំពេញភារកិច្ចដទៃទៀតតាមការណែនាំរបស់រដ្ឋមន្ត្រី។

**ប្រការ៣.-**

គ្រប់ថ្នាក់ដឹកនាំ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធានវិទ្យាស្ថាន ប្រធានគ្រប់អង្គភាព ក្រោមឱវាទក្រសួង ឧ.វ.ប.ន. និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៥កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហែម វណ្ណឌី**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- អង្គភាពអ្នកនាំពាក្យរបស់រាជរដ្ឋាភិបាល
- អង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស ( ទីស្តីការគណៈរដ្ឋមន្ត្រី )
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ